ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០០២ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថាន ឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលមានអក្សរកាត់ “វ.អ.ស” ត្រូវនឹងភាសាអង់គ្លេសថា ( INSTITUE FOR DEVELOPMENT OF ECONOMY ) មានអក្សរកាត់ ( IDE ) ។ វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅអគារលេខ ១២-១៤បេ ផ្លូវលេខ ២៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចមានភារកិច្ចធ្វើការបណ្តុះបណ្តាល :

-ថ្នាក់វិញ្ញាបនបត្រ បណ្តុះបណ្តាលរយៈពេលខ្លីក្រោម ១ឆ្នាំ ទៅតាម ជំនាញវិជ្ជាជីវៈ ។

-ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ។

-ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ។

-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ។

**មាត្រា ៣ :** ចំពោះមុខវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច មានរចនាសម្ព័ន្ធដូចខាងក្រោម :

១- ការិយាល័យសិក្សា

២- ការិយាល័យរដ្ឋបាល

៣- ការិយាល័យបច្ចេកទេស

៤- ការិយាល័យផែនការ និងហិរញ្ញវត្ថុ

៥- ដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម

៦- ដេប៉ាតឺម៉ង់នីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ

៧- ដេប៉ាតឺម៉ង់ភាសាបរទេស

៨- ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា

៩- ដេប៉ាតឺម៉ង់សណ្ឋាគារ និងទេសចរណ៍

១០- ដេប៉ាតឺម៉ង់គណនេយ្យ-ធនាគារ

១១- ដេប៉ាតឺម៉ង់ព័ត៌មានទីផ្សារ

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកដេប៉ាតឺម៉ង់ ឬសាខា ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្សឱ្យចូលរៀន :

- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនទាំង ២ភេទ មានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ កំរិត ៣ ឬបានប្រឡងជាប់ ឬថ្នាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនទាំងពីរភេទ មានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បេក្ខជនទាំង ២ភេទ ត្រូវមានសញ្ញាបត្រវិស្វករ ឬបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀនតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**មាត្រា ៥ :** វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចមាននាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៧ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និងនាយិកាវិទ្យាស្ថាន អភិវឌ្ឍន៍សេដ្ឋកិច្ចមានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ក្រសួងអប់រំ យុវជន និងកីឡា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
-គ្រប់ខេត្ត-ក្រុង
-ដូចមាត្រា៨
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ